**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធ**
**ព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

# ប្រកាសព័ត៌មាន លេខ ១៥ (ខែ ឧសភា ឆ្នាំ ២០១៥)

ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការនឹងចាប់ផ្តើមនៅខែកក្កដាខាងមុខនេះ ជាមួយនឹងមុខងារចំនួនពីររួមមាន សៀវភៅធំ (GL) និងវិភាជន៍ថវិកា (BA) ចំណែកមុខងារដទៃទៀតនឹងចាប់ផ្តើមនៅក្នុងខែតុលា ឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ ក្រុមការងាររួមគ្រោងនឹងបង្ហាញពីប្រព័ន្ធ FMIS ជាក់ស្តែង និងផែនការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជូនដល់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពាក់ព័ន្ធគន្លឹះៗ ដើម្បីឱ្យបានយល់កាន់តែស៊ីជម្រៅលើផែនការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធជាផ្លូវការទាំងក្នុងខែកក្កដា និងនៅក្នុងខែតុលា ឆ្នាំ២០១៥។ ពាក់ព័ន្ធនឹងចំនួន និងឈ្មោះមន្ត្រីដែលត្រូវប្រើប្រាស់ប្រព័ន្ធ FMIS ដោយយោងតាមនីតិវិធី Add និង Confirm ក្រុមការងារកំពុងគិតគូររៀបចំស្នើសុំឱ្យអគ្គនាយកដ្ឋានពាក់ព័ន្ធគន្លឹះជ្រើសរើសមន្ត្រីរបស់ខ្លួនក្នុងចំណោមឈ្មោះមន្ត្រីដែលបានបញ្ជូនមកក្រុមការងារគម្រោងនៃនាយកដ្ឋានព័ត៌មានវិទ្យាសម្រាប់ដំណាក់កាលទី១ជាមុនសិន ដើម្បីរៀបចំដំឡើងបណ្តាញតភ្ជាប់អ្នកប្រើប្រាស់មកប្រព័ន្ធ FMIS ដែលហៅកាត់ថា Wall Point។ ក្រុមការងារផ្នែកមុខងារបានបញ្ចប់ User Acceptance Test លើកទី១ ផ្តោតសំខាន់លើមុខងារសៀវភៅធំ (GL) និងមុខងារវិភាជន៍ថវិកា (BA) ដោយមានការចូលរួមពីអគ្គនាយកដ្ឋាន-នាយកដ្ឋានពាក់ព័ន្ធ ដើម្បីសាកល្បងប្រតិបត្តិការតាមទិន្នន័យជាក់ស្តែង។ ចំណែកឯមុខងារផ្សេងទៀតនឹងអនុវត្តនាពេលបន្ទាប់នៅក្នុងកំឡុងខែកញ្ញា ឆ្នាំ២០១៥ មុនពេលដាក់ឱ្យអនុវត្តគ្រប់មុខងាររបស់ប្រព័ន្ធ។ ការងារពាក់ព័ន្ធនឹងការធ្វើសន្ធានកម្មជាមួយប្រព័ន្ធធនាគារជាតិ ក្រុមការងារបានពិភាក្សាគ្នាអំពីការសាកល្បងប្រព័ន្ធ Electronic Fund Transfer (EFT) រវាងប្រព័ន្ធ FMIS និងប្រព័ន្ធធនាគារជាតិ ដោយទទួលបានការព្រមព្រៀងគ្នាក្នុងការតភ្ជាប់ប្រព័ន្ធ EFT នៅក្នុងប្រព័ន្ធ FMIS រួចជាស្រេចទុកសម្រាប់ការប្រើប្រាស់នាពេលអនាគត។ ជាមួយគ្នានេះក្រុមការងារ Data Conversion កំពុងខិតខំទាញយកទិន្នន័យពីប្រព័ន្ធនានា ដូចជាប្រព័ន្ធ KIT របស់រតនាគារជាតិ ដើម្បីធ្វើការកែសម្រួលឱ្យបាន ត្រឹមត្រូវដើម្បីដាក់ចូលក្នុងប្រព័ន្ធ FMIS សម្រាប់ ការដាក់ឱ្យអនុវត្តនៅខែកក្កដា ឆ្នាំ២០១៥ ខាងមុខនេះ។

ក្រុមការងារគ្រប់គ្រងការផ្លាស់ប្តូរនៅតែបន្តអនុវត្តនិងកែសម្រួលយុទ្ធសាស្ត្រទំនាក់ទំនងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ តាមរយៈគេហទំព័រ កិច្ចប្រជុំ និងព្រឹត្តិការណ៍ផ្សេងៗ ក្នុងគោលបំណងឱ្យអ្នកពាក់ព័ន្ធទាំងអស់យល់ជ្រាបកាន់តែច្បាស់អំពីការផ្លាស់ប្តូរនៃការអនុវត្តគម្រោង អត្ថប្រយោជន៍ផ្សេងៗ និងការត្រៀមខ្លួនសម្រាប់ប្រើប្រាស់ប្រព័ន្ធ FMIS នាពេលដ៏ខ្លីខាងមុខ។ ក្រុមការងារផ្នែកមុខងារបានទទួលវគ្គបណ្តុះបណ្តាលជាគ្រូបង្គោល (Training of Trainer) សម្រាប់មន្ត្រីបង្គោលដើម្បីក្លាយជាមន្ត្រីជំនាញមានសមត្ថភាពផ្តល់វគ្គបណ្តុះបណ្តាលផ្សេងៗសម្រាប់ការអនុវត្តប្រព័ន្ធ FMIS។ ក្រុមការងារហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កំពុងរៀបចំដំឡើងប្រព័ន្ធបណ្តាញនៅតាមទីតាំងដែលបានកំណត់ទុកនិង និងរៀបចំដំឡើង Wall Point ដើម្បីតភ្ជាប់ទៅបណ្តាញប្រព័ន្ធ FMIS ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីដែលត្រូវប្រើប្រាស់ប្រព័ន្ធ FMIS។

## តារាងពេលវេលានៃការអនុវត្តគម្រោង FMIS




**ការងារគន្លឹះ÷**

១). នីតិវិធីអនុវត្តការងារអនាគតសម្រាប់ប្រព័ន្ធ FMIS ត្រូវបានសម្រេចអនុម័តដោយថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២). ត្រៀមអនុវត្តការងារទំនាក់ទំនងផ្សព្វផ្សាយអំពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS នៅខែកក្កដា និងខែតុលា ឆ្នាំ២០១៥

៣). បានប្រមូលទិន្នន័យពីប្រព័ន្ធផ្សេងៗសម្រាប់បញ្ចូលក្នុងប្រព័ន្ធ FMIS ដូចជាប្រព័ន្ធ KIT របស់រតនាគារជាតិ

៤). បញ្ចប់ការស្ថាបនាប្រព័ន្ធ FMIS និងត្រៀមដំឡើងរចនាសម្ព័ន្ធសម្រាប់ប្រព័ន្ធនៅតាមអគ្គនាយកដ្ឋានពាក់ព័ន្ធគន្លឹះ

៥). បញ្ចប់ការកំណត់អ្នកប្រើប្រាស់ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់ការអនុវត្តប្រព័ន្ធ FMIS

៦). កំពុងបញ្ចប់ផែនការអនុវត្តគម្រោងដែលកែសម្រួលសម្រាប់ការអនុវត្តគម្រោង FMIS


សម្រាប់ព័ត៌មានបន្ថែមផ្សេងៗ សូមចូលទៅកាន់គេហទំព័រ ឬទំនាក់ទំនងតាមអ៊ីមែល ឬទូរស័ព្ទដូចខាងក្រោម÷

គេហទំព័រ÷ http://fmis.mef.gov.kh អ៊ីមែល÷ fmis.info@mef.gov.kh ទូរស័ព្ទទំនាក់ទំនង÷ 023 430 063